# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី២៣)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១៥ ៤៨៤ នាក់ នៃរោងចក្រ សហគ្រាស ទាំង៦៦ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីងនឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៦៦ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៦៦ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 34 |
| 1 | ក្រុមហ៊ុន ភើហ្វិក ស៊ីមឡេស ហ្គាម៉ិន (ខេមបូឌា) លីមីធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ជីឌីអឹម អ៊ិនធើប្រាយ | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ស៊ីន ស៊ី អេក អិនហុង (ខេមបូឌា) ប្លាស្ទិក អ៊ិនដាស្ទ្រី | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ស៊ីនចាង ថេក អ៊ីន | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ផានថេសសា ហ្គាមេន (ខេមបូឌា) | ភ្នំពេញ |
| 6 | ក្រុមហ៊ុន យៃនធើរេន អឺភែរឹល (ខេមបូឌា) | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា) | ភ្នំពេញ |
| 8 | ក្រុមហ៊ុន វ៉ាយ អេស ស៊ី យ៉ក់សាន់ ស្តារ (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ហ៊្សូ ឈុន ស៊ូ | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ជាវហ៊ុយ អ៊ិនដាសស្ទ្រៀល | ភ្នំពេញ |
| 11 | ក្រុមហ៊ុន លី ហ្វេតស៍ ហ្គាមេន | ភ្នំពេញ |
| 12 | ក្រុមហ៊ុន យីង ហ្វេសិន ហ្គាមេន | ភ្នំពេញ |
| 13 | ក្រុមហ៊ុន រួយ ដា ស៊ីង ហ្គាម៉ិន | ភ្នំពេញ |
| 14 | ក្រុមហ៊ុន គ័ន ម៉ីង ហ៊ែនប៉ែក (ខេមបូឌា) អ៊ិនដាសស្ទ្រៀល ឯ.ក | កណ្តាល |
| 15 | ក្រុមហ៊ុន ដា រ៉ុង ព្រីនធីង & អ៊ឹមប្រយឌើរី | កណ្តាល |
| 16 | ក្រុមហ៊ុន ញូអាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត | កណ្តាល |
| 17 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 18 | ក្រុមហ៊ុន យីង ហ្វីស អ៊ិនដាសស្ទ្រៀល | កណ្តាល |
| 19 | ក្រុមហ៊ុន ស្តារីត (ខេមបូឌា) ឯ.ក | កណ្តាល |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 20 | ក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន (1) | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុន ថិចសាន់(ខេមបូឌា)នីតធីង វ័ស៊ីង ដាយអ៊ីង អេន ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុន ស៊ីអិនឌីហ្គ្រី អិនធើណេសិនណល (ខេអេច) ឯ.ក | កំពង់ស្ពឺ |
| 23 | ក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 24 | ក្រុមហ៊ុន មីង ហ្វៃ អេនធើប្រាយ(ខេមបូឌា)ឯ.ក. | កំពង់ស្ពឺ |
| 25 | ក្រុមហ៊ុន សាងវ៉ូ ខេមបូឌា ខូអិលធីឌី | កំពង់ស្ពឺ |
| 26 | ក្រុមហ៊ុន ដេស៊ីង ខេមបូ ខូអិលធីឌី | កំពង់ស្ពឺ |
| 27 | ក្រុមហ៊ុន តើហ្វិករីសិន ហ្វេសិន ( ខេមបូឌា) ឯ.ក | តាកែវ |
| 28 | ក្រុមហ៊ុន ប្រាយ ហ្គ្លាស់ស៊ីង ឯ.ក | តាកែវ |
| 29 | ក្រុមហ៊ុន ប៉ុនតឹសហ្វ៊ុតវែរ អិល ធី ឌី | តាកែវ |
| 30 | ក្រុមហ៊ុន អ៊ី-ចេង (ខេមបូឌា) ខបភើរេសិន | តាកែវ |
| 31 | ក្រុមហ៊ុន ខេមបូឌាន ស្កេវ៉ាយដ៍ ស្ព័ត ឯ.ក | ព្រះសីហនុ |
| 32 | ក្រុមហ៊ុន ហ៊ែលសា សៅ អ៊ិស អេស៊ា ខូអិលលធីឌី | ស្វាយរៀង |
| 33 | ក្រុមហ៊ុន យ៉ឹង អ៊ីធើណល (ខេមបូឌា) | ស្វាយរៀង |
| 34 | ក្រុមហ៊ុន អេស.ភី.ប្រាឌើរ (ស៊ីសុផុន) | បន្ទាយមានជ័យ |
| ខ. វិស័យទេសចរណ៍ | | 32 |
| 35 | ក្រុមហ៊ុន ដាវ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 36 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល (1) | ភ្នំពេញ |
| 37 | ក្រុមហ៊ុន ផូគីថវ៉ា រីសត & ស្ប៉ា (ខេមបូឌា) | ភ្នំពេញ |
| 38 | សណ្ឋាគារ វ៉ាហ្វិល រ៉ូយ៉ាល់ | ភ្នំពេញ |
| 39 | ក្រុមហ៊ុន ខាល់ធី ស្ប៉ាយស៍ (ខេមបូឌា)ខូ អិលធីឌី | ភ្នំពេញ |
| 40 | ក្រុមហ៊ុន យូ យូ ត្រាវែល អេជេនស៊ី | ភ្នំពេញ |
| 41 | សណ្ឋាគារ អូឡាំព្យា ស៊ីធី | ភ្នំពេញ |
| 42 | ក្រុមហ៊ុន តូយ៉ូកូ អ៊ីន | ភ្នំពេញ |
| 43 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 44 | ក្រុមហ៊ុន កូបេ យៃភែននីស វ៉េស្ទូរ៉ែន | សៀមរាប |
| 45 | ក្រុមហ៊ុន ផេង វ៉េស៊ីដេន | សៀមរាប |
| 46 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 47 | ក្រុមហ៊ុន វ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 48 | ក្រុមហ៊ុន ដឹ សុទ្ធា (ខេ.វី) ភីធីអ៊ី អិលធីឌី | សៀមរាប |
| 49 | សណ្ឋាគារគោព្រៃ | សៀមរាប |
| 50 | ក្រុមហ៊ុន ដឹ ឃ្លៀប្ល៊ូមូន | សៀមរាប |
| 51 | ក្រុមហ៊ុន សេនត្រលស៊ីតរេស៊ីដេនស៍ | សៀមរាប |
| 52 | ក្រុមហ៊ុន ដឹ ប្លែក សាន់ រេសថឺរេន អេន បារ ខូ អិលធីឌី | សៀមរាប |
| 53 | ផ្ទះសំណាក់ សាតូអង្គ | សៀមរាប |
| 54 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវ៉ែល ស៊ែរវីស | សៀមរាប |
| 55 | ក្រុមហ៊ុន ដឹ អេវៀរី | សៀមរាប |
| 56 | ក្រុមហ៊ុន រ៉ូយ៉ាល់អង្គរ (សណ្ឋាគារសូហ្វីតែលអង្គរភូគីត្រាហ្គោហ្វ & ស្ប៉ារីហ្សត) | សៀមរាប |
| 57 | ក្រុមហ៊ុន អេស៊ាស្មាត ធួរ | សៀមរាប |
| 58 | ភោជនីយដ្ឋាន វិរតន៍ | សៀមរាប |
| 59 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 60 | ក្រុមហ៊ុន ហាប់ ហេង អ៊ិនវេសមេន ភីធីអ៊ី អិលធីឌី | សៀមរាប |
| 61 | ក្រុមហ៊ុន វិរតន៍ វីឡា | សៀមរាប |
| 62 | សណ្ឋាគារ វិរតន៍ | សៀមរាប |
| 63 | ក្រុមហ៊ុន អេរីតាស ll | សៀមរាប |
| 64 | សណ្ឋាគារវិត្តូរីយ៉ាអង្គរ រីសត និង ស្ប៉ា | សៀមរាប |
| 65 | ក្រុមហ៊ុន រេសថឺរេន ខូឡិចហ្សិន | សៀមរាប |
| 66 | ក្រុមហ៊ុន ប្រូខន អ៊ិនវេសមេន ខូ អិលធីឌី | ព្រះសីហនុ |